NEWS RELEASE

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# ការិយាល័យសិទ្ធិមនុស្ស អ.ស.ប សូមស្វាគមន៍ការបោះឆ្នោតឃុំ/សង្កាត់ដែលប្រព្រឹត្តទៅប្រកបដោយសណ្តាប់ធ្នាប់ល្អនៅកម្ពុជា និងសូមអំពាវនាវឲ្យបើកឡើងវិញនូវលំហសង្គមស៊ីវិល

ទីក្រុងបាងកក (៧ មិថុនា ២០១៧) - ការិយាល័យសិទ្ធិមនុស្ស អ.ស.បប្រចាំតំបន់អាស៊ីអាគ្នេយ៍បានស្វាគមន៍ការប្រព្រឹត្តទៅប្រកបដោយសណ្តាប់ធ្នាប់ល្អក្នុងការបោះឆ្នោតឃុំ/សង្កាត់ដែលបានធ្វើឡើងនៅទូទាំងប្រទេសកម្ពុជានៅថ្ងៃទី០៤ ខែមិថុនាហើយបានសម្តែងក្តីសង្ឃឹមថាការបោះឆ្នោតនឹងប្រព្រឹត្តទៅដោយរលូននិងដោយសន្តិវិធីសម្រាប់ដំណើរការប្រជាធិបតេយ្យនៅមុខពេលនៃការបោះឆ្នោតជាតិឆ្នាំក្រោយ។

អ្នកស្រី កាទីយ៉ា ស៊ីរីហ្ស៊ី (Katia Chirizzi) តំណាងរងប្រចាំតំបន់នៃការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍នៅទីក្រុងបាងកក បានមានប្រសាន៍ថា៖"យើងមានសេចក្តីរីករាយដែលបានឃើញថាអំពើហឹង្សា អន្តរាគមន៍យោធា និងការចាប់ខ្លួន ដែលត្រូវបានគំរាមនៅមុនពេលនៃការបោះឆ្នោត មិនបានកើតមានទេ ហើយថា ប្រជាជនកម្ពុជាបានសម្តែងនូវការពេញចិត្តជាទូទៅចំពោះដំណើរការនេះ"។

ការិយាល័យសិទ្ធិមនុស្ស អ.ស.ប បានឃ្លាំមើលបរិយាកាសសិទ្ធិមនុស្សនៃការបោះឆ្នោត ដូចដែលខ្លួនបានធ្វើនៅរៀងរាល់ការបោះឆ្នោតចាប់តាំងពីការិយាល័យនេះបានបង្កើតនៅទីនោះក្នុងឆ្នាំ១៩៩៣។ ការិយាល័យនេះ បានអបអរសាទរចំពោះការពិតដែលថាវាមានលក្ខណៈផ្ទុយគ្នានឹងការបោះឆ្នោតកាលពីពេលកន្លងមក គឺនាពេលនេះ មិនមានអ្នកបោះឆ្នោតណាបានអះអាងថាពួកគេត្រូវបានរាងរាំងមិនឲ្យបោះឆ្នោតឡើយ។

ការិយាល័យប្រចាំតំបន់បានអបអរសាទរចំពោះប្រជាជនកម្ពុជាដែលបានចេញទៅបោះឆ្នោតក្នុងចំនួនដ៏ខ្ពស់អង្គការសង្គមស៊ីវិលដែលបានដាក់ពង្រាយបុគ្គលិកយ៉ាងច្រើនដើម្បីពិនិត្យពិច័យលើការបោះឆ្នោតគ្រប់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតនិងចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលើការរៀបចំរបស់ខ្លួន។

ទោះយ៉ាងណាក៏ដោយ របាយការណ៍ជាច្រើនដែលបានទទួលនៅមុនពេលនៃការបោះឆ្នោត គឺថាមានអ្នកនយោបាយគណបក្សប្រឆាំងមួយចំនួន មានការគំរាមកំហែងនិងរារាំងមិនឲ្យធ្វើយុទ្ធនាការបោះឆ្នោត ហើយថាមានអ្នកឃ្លាំមើលការបោះឆ្នោតមួយចំនួនមកពីសង្គមស៊ីវិល បានរងការបំភិតបំភ័យ និងយាយីរំខាន។

"ដោយបានធ្វើការរៀបចំបានល្អសម្រាប់ការបោះឆ្នោតយើងជឿជាក់ថាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានធ្វើកំណែទម្រង់រួចហើយនេះនឹងអាចដោះស្រាយរាល់បណ្តឹងទាក់ទងនឹងការបោះឆ្នោតដែលបានដាក់ស្នើឲ្យគណៈកម្មាធិការនេះពិនិត្យដោះស្រាយដោយអនុលោមតាមច្បាប់យ៉ាងខ្ជាប់ខ្ជួន រាប់ទាំងសិទ្ធិមនុស្សដែលបានបង្កើតឡើងជាអន្តរជាតិ ដើម្បីចូលរួមក្នុងកិច្ចការសាធារណៈផង" អ្នកស្រី កាទីយ៉ា ស៊ីរីហ្ស៊ី បានមានប្រសាសន៍ដូច្នេះដោយសង្កត់ធ្ងន់ពីសារៈសំខាន់

នៃការការពារមិនឲ្យកើតជាថ្មីនូវឥរិយាបទគំរាមកំហែងនៅមុនពេលនៃការបោះឆ្នោតជាតិឆ្នាំ២០១៨។

"ការបោះឆ្នោតបានកំណត់ផែនគ្រឹះថ្មីក្នុងតម្លាភាពទោះបីជាមានការបង្ហាញពីវិធីមួយចំនួនដែលក្នុងនោះដំណើរការនេះអាចនឹងត្រូវបានពង្រឹងបន្ថែមទៀតនៅឆ្នាំក្រោយក៏ដោយ។ ជាពិសេស ការគំរាមកំហែងខាងនយោបាយ និងការចាប់ខ្លួនតួអង្គសង្គមស៊ីវិល និងសមាជិកគណបក្សប្រឆាំង គួរតែបញ្ឈប់ ដើម្បីឲ្យពួកគេអាចបន្តដើរតួនាទីស្របច្បាប់របស់ខ្លួន ទៅតាមសមត្ថភាពរៀងៗខ្លួន នៅក្នុងប្រទេសកម្ពុជាតាមបែបប្រជាធិបតេយ្យមួយ ជាពិសេស នៅមុនពេលនៃការបោះឆ្នោតនៅឆ្នាំក្រោយ។ ការដោះលែង "មន្ត្រីអាដហុកទាំង ៥ រូប" និងអ្នកស្រី ទេព វន្នី គឺជាតេស្តដ៏សំខាន់នៃលំហនោះ"។

ចប់

*សម្រាប់ការសាកសួរព័ត៌មាន សូមទំនាក់ទំនងមកលោក ចេរមី ឡូរិន ( Jeremy Laurence)*
*តាមរយៈទូរស័ព្ទលេខ (+៦៦ ៨៤ ៧០០ ៤៦៧១ / laurencej@un.org)*

**សម្រាប់វេបសាយព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អ្នក៖**
សារគន្លឹះៗអំពីសេចក្តីប្រកាសព័ត៌មានរបស់យើងអាចរកបាននៅលើបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមសិទ្ធិមនុស្ស អ.ស.ប ដូចមានរាយខាងក្រោមនេះ។ សូមថេក (tag) មកយើងដោយប្រើចំណុចទាញត្រឹមត្រូវ

ទ្វីតធឺ៖ OHCHRAsiahttp://twitter.com/UNrightswire
ហ្វេសប៊ុក៖ UNHumanRightsAsia
ហ្គោហ្គឺល+៖ unitednationshumanrights
យូធូប៖ unohchr

*ការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍នៅទីក្រុងបាងកកតំណាងឲ្យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅតំបន់អាស៊ីអាគ្នេយ៍។ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សគឺជាមន្ត្រីសិទ្ធិមនុស្សសំខាន់បំផុតរបស់អង្គការសហប្រជាជាតិ និងជាប្រធានការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលដឹកនាំកិច្ចខិតខំប្រឹងប្រែងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។*

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
ការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍
ESCAP អគារលេខាធិការដ្ឋាន អ.ស.ប
ជាន់ទី៦ ប្លុក ក
រុក្ខវិថី រាជដាមនឿន នុក ទីក្រុងបាងកក ១០២០០
ទូរស័ព្ទលេខ(៦៦២) ២៨៨ ១២៣៥ ទូរសារលេខ(៦៦២) ២៨៨ ១០ ៣៩
វេបសាយ៖ http://bangkok.ohchr.org
អ៊ីម៉ែល៖ ohchr.bangkok@un.org